ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

## គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ

## ប្រចាំក្រសួងយុត្តិធម៌ ( JICA )

## ជំនាញការផ្នែកច្បាប់៖ អ៊ីសូអ៊ី មីហា

ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៤

ថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ ២០១៤
គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ
ប្រចាំក្រសួងយុត្តិធម៌ (JICA)
ជំនាញការផ្នែកច្បាប់ ៖ អ៊ីសូអ៊ី មីហា

# កិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ

## ១. សេចក្ដីផ្ដើម

តើអ្វីទៅជាកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ?

តើអ្វីទៅជាគោលបំណងនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ?

## ២. ប្រព័ន្ធទ្រព្យសម្បត្តិប្ដីប្រពន្ធ

(១) ប្រព័ន្ធទ្រព្យសម្បត្តិតាមច្បាប់ ៖ ប្រព័ន្ធទ្រព្យសម្បត្តិរួម (មាត្រា ៩៧៣)

ក្រៅពីទ្រព្យសម្បត្តិដែលមានមុនពេលរៀបអាពាហ៍ពិពាហ៍ និង ទ្រព្យសម្បត្តិដែលទទួលបានដោយសារសន្តតិកម្ម ឬប្រទានកម្មក្រោយរៀបអាពាហ៍ពិពាហ៍ គឺជាទ្រព្យសម្បត្តិរួម។

ប្រព័ន្ធទ្រព្យសម្បត្តិប្ដីប្រពន្ធរបស់ប្រទេសផ្សេងៗ ៖

- ប្រព័ន្ធទ្រព្យសម្បត្តិរួមសកល (Coverture / Universal community property) ៖ សហព័ទ្ធម្ខាងមានកម្មសិទ្ធិ និងគ្រប់គ្រងទៅលើទ្រព្យសម្បត្តិទាំងអស់ ឬ មានសិទ្ធិរួមគ្នាលើទ្រព្យសម្បត្តិទាំងអស់ ។
- ប្រព័ន្ធទ្រព្យសម្បត្តិដោយឡែក (Separate property system) ៖ ម្នាក់ៗមានកម្មសិទ្ធិ និងគ្រប់គ្រងដោយឯករាជ្យលើទ្រព្យសម្បត្តិ (ជប៉ុន, អាល្លឺម៉ង់)
- ប្រព័ន្ធទ្រព្យសម្បត្តិរួម (Community property system)៖
  - ប្រព័ន្ធទ្រព្យរួម ៖ ក្រៅពីទ្រព្យដោយឡែក ទ្រព្យសម្បត្តិដែលប្ដីប្រពន្ធទទួលបាន គឺជាកម្មសិទ្ធិរួម (កម្ពុជា, បារាំង)
  - ប្រព័ន្ធទ្រព្យរួមដែលត្រូវបានកម្រិត ៖ យកគោលការណ៍នៃប្រព័ន្ធទ្រព្យសម្បត្តិដោយឡែកដោយម្នាក់ៗឯករាជ្យ ប៉ុន្តែ ក្រោយពេលបញ្ចប់អាពាហ៍ពិពាហ៍ ត្រូវបែងចែកដោយពិចារណាទៅលើសមភាពជាក់ស្ដែង។

(២) ទ្រព្យសម្បត្តិដោយឡែង និងទ្រព្យសម្បត្តិរួម

**ទ្រព្យសម្បត្តិដោយឡែក (មាត្រា ៩៧២)**

ទ្រព្យសម្បត្តិ ដែលសហព័ទ្ធមាន នៅមុនពេលរៀបអាពាហ៍ពិពាហ៍ (ចំនុច ក)

ទ្រព្យសម្បត្តិ ដែលសហព័ទ្ធទទួលបាន ដោយប្រទានកម្ម សន្តតិកម្ម អច្ច័យទាន នៅក្នុងអំឡុងពេលរៀបអាពាហ៍ពិពាហ៍ (ចំនុច ខ)

ទ្រព្យសម្បត្តិជាតម្លៃតប ដែលទទួលបានពីការចាត់ចែងទ្រព្យសម្បត្តិដែលបានកំណត់ក្នុង ចំនុច ក និង ចំនុច ខ ខាងលើនេះ (ចំនុច គ)

**ទ្រព្យសម្បត្តិរួម (មាត្រា ៩៧៣)**

ទ្រព្យសម្បត្តិទាំងឡាយ ដែលប្តីប្រពន្ធទាំងសងខាង ឬ តែម្ខាង ទទួលបាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ លើកលែងតែទ្រព្យសម្បត្តិដែលកំណត់ក្នុងចំនុច ខ និងចំនុច គ នៃមាត្រា ៩៧២។

ទ្រព្យដែលមើលឃើញថាជាលទ្ធផលនៃពលកម្មរួម នៅក្នុងជីវភាពរបស់ប្តីប្រពន្ធ គឺជាទ្រព្យសម្បត្តិរួម ហើយទ្រព្យដែលមិនអាចគិតថាជាលទ្ធផលនៃពលកម្មរួមរបស់ប្តីប្រពន្ធ ឬទ្រព្យដែលទទួលបានផ្ទាល់ខ្លួន គឺជាទ្រព្យដោយឡែក។

**"ឧទាហរណ៍នៃទ្រព្យដោយឡែក"**

- ចំណូល ឬ ប្រាក់ខែដែលទទួលបានមុនរៀបអាពាហ៍ពិពាហ៍
- ប្រាក់សន្សំនៅក្នុងធនាគារដែលជាចំណូលមុនរៀបអាពាហ៍ពិពាហ៍
- ការប្រាក់ដែលកើតពីគណនីធនាគារខាងលើ
- ទ្រព្យសម្បត្តិដូចជាដីជាដើម ដែលធ្វើសន្តតិកម្មពីឪពុកម្តាយមុនពេល ឬក្រោយពេលរៀបអាពាហ៍ពិពាហ៍
- ទ្រព្យសម្បត្តិដែលទទួលបានពីប្រទានកម្មជាលក្ខណៈឯកជនក្រោយពេលរៀបអាពាហ៍ពិពាហ៍

**"ឧទាហរណ៍នៃទ្រព្យរួម"**

- ចំណូល ឬ ប្រាក់ខែ ដែលរកបានក្រោយពេលរៀបអាពាហ៍ពិពាហ៍
- ទ្រព្យសម្បត្តិដែលបានទិញដោយប្រើប្រាស់ចំណូលដែលរកបានក្រោយរៀបអាពាហ៍ពិពាហ៍
- វត្ថុដែលផ្ញើឲ្យជាលក្ខណៈប្រទានកម្មចំពោះប្តីប្រពន្ធក្រោយពេលរៀបអាពាហ៍ពិពាហ៍

❖ ករណីដែលប្តីមានគោមុនពេលរៀបអាពាហ៍ពិពាហ៍ ហើយប្រពន្ធបានមើលថែទាំរហូត គោនោះបានកើតកូនគោ តើកូនគោនោះគឺជាទ្រព្យរួម ឬ ទ្រព្យដោយឡែក?
ករណីដែលអាចកំណត់ថា ជាលទ្ធផលដែលកើតចេញពីពលកម្មរួមរបស់ប្តីប្រពន្ធ នោះអាចគិតថា ជាទ្រព្យរួមបាន។

❖ ករណីដែលមានចំណូលពីការជួលផ្ទះ ឬផ្ទះសំណាក់ ដែលគ្រប់គ្រងដោយប្តីប្រពន្ធរួមគ្នា លើអចលនវត្ថុដែលជាកម្មសិទ្ធិរបស់សហព័ទ្ធណាម្ខាងតាំងពីមុនពេលរៀបអាពាហ៍ពិពាហ៍ ក៏ដូចគ្នាដែរ។

(៣) ការចាត់ចែងក្នុងករណីលែងលះ

ការបែងចែកទ្រព្យសម្បត្តិ (មាត្រា ៩៨០)

១-ក្នុងករណីដែលប្តីប្រពន្ធលែងលះគ្នា ត្រូវបែងចែកទ្រព្យសម្បត្តិ ដោយយុត្តិធម៌ផ្អែកតាមការពិភាក្សារបស់ភាគីទាំងសងខាង ។

២-ក្នុងករណីដែលមិនអាចពិភាក្សាគ្នារវាងប្តីប្រពន្ធបានទេ ត្រូវបែងចែកទ្រព្យសម្បត្តិ ដោយផ្អែកតាមចំណុចនីមួយៗ ដូចកំណត់ខាងក្រោមនេះ :

ក-សហព័ទ្ធនីមួយៗ ត្រូវទទួលបាននូវទ្រព្យសម្បត្តិដោយឡែកដែលបានកំណត់នៅក្នុងមាត្រា ៩៧២ (ទ្រព្យសម្បត្តិដោយឡែក) ។

ខ-បន្ថែមពីលើទ្រព្យសម្បត្តិដោយឡែក សហព័ទ្ធនីមួយៗ មានសិទ្ធិទទួលយក ១ ភាគ ២ (មួយភាគពីរ) នៃទ្រព្យសម្បត្តិរួម ។ ប៉ុន្តែ បើមានករណីពិសេស និង មានការទាមទាររបស់ប្តីប្រពន្ធណាម្ខាង តុលាការក៏អាចបែងចែកទ្រព្យសម្បត្តិរួម ដោយពិចារណាទៅលើស្ថានភាពផ្សេងៗដូចជា ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗ ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗចំពោះលទ្ធកម្មនៃទ្រព្យសម្បត្តិ ការថែរក្សា ឬ ការបង្កើនទ្រព្យអំឡុងពេលអាពាហ៍ពិពាហ៍ កម្រិតជីវភាពរស់នៅនៅក្នុងពេល មានចំណងអាពាហ៍ពិពាហ៍ អាយុ ស្ថានភាពផ្លូវចិត្តនិងផ្លូវកាយ វិជ្ជាជីវៈ ប្រាក់ចំណូល លទ្ធភាពធ្វើការងាររបស់ភាគីនីមួយៗ និង ផលប្រយោជន៍របស់កូន ជាអាទិ៍ ។

៣-គេហកិច្ច ត្រូវចាត់ទុកថាមានតម្លៃស្មើនឹងការងារដែលធ្វើក្រៅផ្ទះដែរ ។

(៤) ករណីសន្តតិកម្ម

ទាក់ទងនឹងទ្រព្យរួម គឺចំណែករបស់សហព័ទ្ធដែលទទួលមរណភាព នឹងត្រូវបែងចែកទៅឲ្យសន្តតិជនដោយរួមបញ្ចូលទាំងសហព័ទ្ធដែលនៅរស់ផងដែរ។

បញ្ញត្តិទាក់ទងនឹងចំណែកមត៌កតាមច្បាប់របស់សហព័ទ្ធ ៖ មាត្រា ១១៦១ នៃក្រមរដ្ឋប្បវេណី

## ៣. កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

ករណីដែលកំណត់ផ្ទុយពីប្រព័ន្ធទ្រព្យរួមដែលមានចែងខាងលើ គឺមានសុពលភាព។

អាចបង្កើតមុនពេល ឬ អំឡុងពេលកំពុងរៀបអាពាហ៍ពិពាហ៍ក៏បាន ហើយក៏អាចផ្លាស់ប្តូរបានដែរ។

ប្រភេទសំខាន់ៗនៃកិច្ចសន្យា

១. ដើមឡើយ ជាទ្រព្យដោយឡែក ដាក់ឲ្យទៅជាទ្រព្យរួម

ឧទាហរណ៍ ៖ ការប្រាក់នៃប្រាក់សន្សំក្នុងធនាគារនៅពេលខ្លួននៅលីវ ដាក់ជាទ្រព្យរួម

ចំណូលថ្លៃឈ្នួលដែលបានមកពីអចលនវត្ថុដែលជាទ្រព្យដោយឡែក ដាក់ជាទ្រព្យរួម

២. ដើមឡើយ ជាទ្រព្យរួម ដាក់ឲ្យទៅជាទ្រព្យដោយឡែក

ឧទាហរណ៍ ៖ ចំណូល ឬ ប្រាក់ខែរបស់ប្តីប្រពន្ធម្នាក់ៗ ដាក់ជាទ្រព្យដោយឡែករៀងៗខ្លួន

(ប៉ុន្តែ ផ្អែកតាមមាត្រា ៩៦៩ កថាខណ្ឌទី ១ ដើម្បីកុំឲ្យរួមផុតពីអាហារកាតព្វកិច្ច នៅពេលដែលសហព័ទ្ធណាម្ខាងបានបាត់បង់ចំណូល នោះសហព័ទ្ធម្ខាងទៀត ត្រូវទ្រទ្រង់ជាចាំបាច់)

៣. កំណត់អំពី ទំនាក់ទំនងកាតព្វកិច្ច និងសិទ្ធិលើបំណុល ជាពិសេស ការចាត់ចែងកាតព្វកិច្ចដែលមានមុនពេលរៀបអាពាហ៍ពិពាហ៍ បន្ទុកនៃកាតព្វកិច្ចជាក់លាក់ដែលអាចនឹងកើតឡើងក្រោយរៀបអាពាហ៍ពិពាហ៍ជាអាទិ៍។

៤. កំណត់ពីសិទ្ធិគ្រប់គ្រង និងចាត់ចែងទ្រព្យសម្បត្តិជាអាទិ៍ (ដូចជា សិទ្ធិគ្រប់គ្រងអចលនវត្ថុដែលជាទ្រព្យដោយឡែករបស់ប្តី ឲ្យទៅប្រពន្ធជាដើម)។

* ការកម្រិតដោយច្បាប់

មិនអាចបំពានដល់សិទ្ធិទាមទារអាហារកាតព្វកិច្ច និងភាគបម្រុងបានទេ (មាត្រា ៩៦៩ កថាខណ្ឌទី ១)

* ខ្លឹមសារអាចមានភាពផ្ទុយនឹងសណ្តាប់ធ្នាក់សាធារណៈ (មាត្រា ៣៥៧)

ករណីដែលមានការព្រមព្រៀងថា ទ្រព្យសម្បត្តិដែលទទួលបានក្រោយរៀបអាពាហ៍ពិពាហ៍ទាំងអស់ ត្រូវក្លាយជារបស់សហព័ទ្ធម្ខាង។ ករណីនេះ បើមើលពីគំនិតនៃសមភាពបុរសស្ត្រី គឺមិនត្រូវបានអនុញ្ញាតទេ។

## ៤. ប្រព័ន្ធចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

ដោយសារតែមានភាពផ្ទុយគ្នានឹងប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ ហេតុនេះចាំបាច់ត្រូវមានការបង្ហាញជាសាធារណៈ។

ក្នុងករណីដែលប្តីប្រពន្ធបានធ្វើកិច្ចសន្យា ផ្សេងពីប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ បើមិនបានចុះបញ្ជីទេ មិនអាចយកកិច្ចសន្យានោះមកតតាំងជាមួយនឹងតតិយជនបានឡើយ (មាត្រា ៩៧០ កថាខណ្ឌទី ២)

ប្រសិនបើខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ មិនបានចុះបញ្ជីទេ នោះមិនអាចអះអាងចំពោះតតិយជនបានោះឡើយ។

ហេតុនេះ ទើបយើងបានរៀបចំប្រកាសថ្មីទាក់ទងនឹងប្រព័ន្ធចុះបញ្ជីនេះនៅក្នុងនាយកដ្ឋានកិច្ចការរដ្ឋប្បវេណីនៃក្រសួងយុត្តិធម៌។

* ទោះបីជាពុំបានចុះបញ្ជីក៏ដោយ ក៏មានសុពលភាពរវាងប្តីប្រពន្ធដែរ (ប៉ុន្តែ យោងតាមមាត្រា ៩៧០ កថាខណ្ឌទី ១ ចាំបាច់ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ)

ឧទាហរណ៍ ៖ ចំណូលរបស់ប្តី ក្នុង ១ខែ ៥០០ ចំណែកឯចំណូលរបស់ប្រពន្ធក្នុង ១ខែ ១០០០ ដែលដើមឡើយវានឹងក្លាយជាទ្រព្យរួម ប៉ុន្តែអ្នកទាំងពីរបានព្រមព្រៀងថាដាក់ជាទ្រព្យដោយឡែករៀងៗខ្លួន។ ករណីម្ចាស់បំណុលរបស់ប្តី (ករណីដែលមិនមែនជាកាតព្វកិច្ចដោយសាមគ្គីតាមរយៈមាត្រា ៩៧៥ ទេ) ចង់រឹបអូសចំណូលរបស់ប្រពន្ធពាក់កណ្តាល ដោយអះអាងថាជាទ្រព្យរួម តើប្រពន្ធអាចអះអាងថា ចំណូល ១០០០ នោះគឺជាទ្រព្យដោយឡែករបស់ខ្លួនបានដែរ ឬទេ?

→ ប្រសិនបើមិនបានចុះបញ្ជីទេ មិនអាចអះអាងបានទេ។

## ៥. ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

ផ្អែកតាមមាត្រា ២៧ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី

# របៀបវារៈ
# សិក្ខាសាលាផ្សព្វផ្សាយប្រកាសស្តីពី
# "នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ"

ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ ២០១៤

នៅសណ្ឋាគារ សាន់វ៉េ រាជធានីភ្នំពេញ

| | | |
|---|---|---|
| ០៧:៣០-០៨:០០ | : | ការចុះឈ្មោះ |
| ០៨:០០-០៨:៣០ | : | ការអញ្ជើញមកដល់ពីសំណាក់ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ |
| ០៨:០០-០៨:៣០ | : | ការអញ្ជើញមកដល់របស់ **ឯកឧត្តម សួរ ចាន់ធី** អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ |
| ០៨:៣០-០៩:០០ | : | - ការប្រកាសបើកកម្មវិធី<br>- គោរពភ្លេងជាតិនៃព្រះរាជាណាចក្រកម្ពុជា<br>- សុន្ទរកថាបើកសិក្ខាសាលាដោយ **ឯកឧត្តម សួរ ចាន់ធី** អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ |
| ០៩:០០-១០:០០ | : | បទបង្ហាញអំពី **"ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ"** |
| ១០:០០-១០:៣០ | : | សម្រាកពិសារអាហារសម្រន់ |
| ១០:៣០-១១:០០ | : | បន្តបទបង្ហាញអំពី **"ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ"** |
| ១១:០០-១១:២០ | : | វគ្គសំនួរ និង ចម្លើយ |
| ១១:២០-១១:៣០ | : | ប្រកាសបិទកម្មវិធី |

រក្សាសិទ្ធិកែប្រែក្នុងករណីចាំបាច់